**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ [illegible] សហវ.អថ

ថ្ងៃពុធ ១រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៩

**ជម្រាបជូន**
**ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

**កម្មវត្ថុ** : ករណីសំណើសុំអនុម័តការចរចាថ្លៃ និងប្រគល់កិច្ចសន្យាស្តីពីការងារស្ថាបនាផ្លូវដោយក្រាលកៅស៊ូ DBST ប្រវែង ៥ 000ម ទទឹង ៦ម ចិញ្ចើមក្រាលល្បាយថ្មភ្នំ ទទឹង ០,៥ម សងខាង គូសគំនូសសញ្ញាចរាចរណ៍ ទំហំ ៣០០ម² និងបំពាក់ស្លាកព័ត៌មានគម្រោង ចំនួន ០២ស្លាក លើកំណាត់ផ្លូវខេត្តចាប់ពីគ.ម១៣+០៤០ ដល់គ.ម១៨+០៤០ បំបែកពីផ្លូវជាតិលេខ៥៧បេ១ ត្រង់គ.ម៣៥+000 ក្នុងភូមិប្លូរ ឃុំប្លូរ ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង។

**យោង** :
- លិខិតលេខ១២៨០០ សហវ.អថ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- កំណត់ហេតុចរចាថ្លៃថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៩ របស់ គ.ល ក្រសួងសាធារណការ និងដឹកជញ្ជូន
- លិខិតលេខ២២៨៤ សក.អល ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៩ របស់ក្រសួងសាធារណការ និងដឹកជញ្ជូន។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមទេសរដ្ឋមន្ត្រីជ្រាបថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ យល់ព្រមតាមសំណើរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ប្រគល់កិច្ចសន្យាជូននាយកដ្ឋានវិស្វកម្ម ក្រសួងការពារជាតិ ដើម្បីធ្វើការងារស្ថាបនាផ្លូវដោយក្រាលកៅស៊ូ DBST ប្រវែង ៥ 000ម ទទឹង ៦ម ចិញ្ចើមក្រាលល្បាយថ្មភ្នំ ទទឹង ០,៥ម សងខាង គូសគំនូសសញ្ញាចរាចរណ៍ ទំហំ ៣០០ម² និងបំពាក់ស្លាកព័ត៌មានគម្រោង ចំនួន ០២ស្លាក លើកំណាត់ផ្លូវខេត្តចាប់ពីគ.ម១៣+០៤០ ដល់គ.ម១៨+០៤០ បំបែកពីផ្លូវជាតិលេខ៥៧បេ១ ត្រង់គ.ម៣៥+000 ក្នុងភូមិប្លូរ ឃុំប្លូរ ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ក្នុងតម្លៃសរុបចំនួន ១.៨៩០.000.000រៀល (មួយប៊ីលានប្រាំបីរយកៅសិបលានរៀលគត់) ជាតម្លៃកិច្ចសន្យា។

ការផ្ទេរបន្តទៅឱ្យក្រុមហ៊ុនឯកជនត្រូវបានហាមឃាត់ដាច់ខាត។ បើអង្គភាពរដ្ឋណាមួយគ្មានលទ្ធភាពធ្វើខ្លួនឯងបាន ត្រូវដកហូតប្រគល់ឱ្យអង្គភាពរដ្ឋមួយទៀតជាអ្នកអនុវត្តវិញ។ ក្នុងករណីប្រគល់ឱ្យអង្គភាពរដ្ឋមួយទៀតជាអ្នកអនុវត្ត ត្រូវស្នើសុំការយល់ព្រមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមុនសិន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមទេសរដ្ឋមន្ត្រីជ្រាប និងមានវិធានការអនុវត្តបន្តឱ្យសមស្របតាមនីតិវិធីលទ្ធកម្មសាធារណៈតាមការគួរ។

សូមឯកឧត្តមទេសរដ្ឋមន្ត្រី ទទួលនូវគារវកិច្ចពីខ្ញុំ។

ជ.ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
រដ្ឋលេខាធិការ

ជូ វិជិត្ត

ចម្លងជូន
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- អគ្គនាយកដ្ឋានថវិកា
- សាលាខេត្តបាត់ដំបង
- នាយកដ្ឋានវិស្វកម្ម ក្រសួងការពារជាតិ
- នាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធសាធារណៈ
- មន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្តបាត់ដំបង
- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ខេត្តបាត់ដំបង
- ឯកសារ-កាលប្បវត្តិ